ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆ្នាំ២០២១នេះ ការងារបង្កបង្កើនផលមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ២ ៩០១ ៦០៥ហ.ត ស្មើនឹង១១១,២១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ២០២១នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗ ឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ដែលសម្រេចបានឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សាបញ្ចប់

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៩២៥ ៨២៨ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៦ ៦២៤ហ.ត ស្មើនឹង០,៥៧% និងដោយគ្រឿងយន្តចំនួន ២ ៩០៩ ២០៤ហ.ត ស្មើនឹង៩៩,៤៣%
- ផ្ទៃដីសាបសម្រេចបានចំនួន ១២ ៣៩២ហ.ត តិចជាងឆ្នាំមុនចំនួន ៣ ៤០១ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៩០១ ៦០៥ហ.ត ស្មើនឹង១១១,២១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ៩៤ ៩៨២ហ.ត។

#### ១.២ ការប្រមូលផលស្រូវរដូវវស្សា

ការប្រមូលផលស្រូវសម្រេចចំនួន ២ ៧៨២ ៩៤៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៩ ០៦០ ៤៩៥តោន លើសឆ្នាំមុនចំនួន ៨៤០ ៨១៨តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,២៥៦តោន/ហ.ត។

#### ១.៣ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៤៧៤ ៥៩២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១ ៥៣៩ហ.ត ស្មើនឹង០,៣២% និងដោយគ្រឿងយន្តមានចំនួន ៤៧៣ ០៥៣ហ.ត ស្មើនឹង៩៩,៦៨%
- ផ្ទៃដីសាបសម្រេចបានចំនួន ៥ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៤៦៧ ០៩៨ហ.ត ស្មើនឹង១០១,០៤% នៃផែនការចំនួន ៤៦២ ២៨០ហ.ត តិចជាងឆ្នាំមុនចំនួន ២៨ ៨០៩ហ.ត។

#### ១.៤ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ២០ ០៣៣ហ.ត ស្មើនឹង៥៦,០២% នៃផែនការចំនួន ៣៥ ៧៦០ហ.ត តិចជាងឆ្នាំមុន ៤ ២១៦ហ.ត

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៤៨ ១៩៦ហ.ត ស្មើនឹង៥៣,៦៦% នៃផែនការចំនួន ៨៩ ៨១០ហ.ត តិចជាងឆ្នាំមុន ៥ ១៧៦ហ.ត។

## ១.៥ ការនាំចេញផលិតផលកសិកម្ម

### ១.៥.១ ការនាំចេញអង្ករ

- ការនាំចេញអង្ករក្នុងខែធ្នូ ឆ្នាំ២០២១ មានចំនួន ៨៤ ៨៩០តោន មានការថយចុះចំនួន ៤ ៨៩៤តោន (-៥,៤៥%) បើធៀបនឹងខែធ្នូ ឆ្នាំ២០២០ ដែលមានចំនួន ៨៩ ៧៨៤តោន

- បរិមាណអង្ករនាំចេញក្នុងឆ្នាំ២០២១ មានចំនួន ៦១៧ ០៦៩តោន មានការថយចុះចំនួន ៧៣ ៧៦០តោន (-១០,៦៨%) បើធៀបនឹងបរិមាណនាំចេញក្នុងឆ្នាំ២០២០ ដែលមានចំនួន ៦៩០ ៨២៩តោន

- ក្នុងឆ្នាំ២០២១ បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២២ប្រទេស មានបរិមាណសរុបចំនួន ១៥៥ ៧៧៣តោន (ថយចុះចំនួន ៤៨ ០១៨តោន ស្មើនឹង -២៣,៥៦%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ៣០៩ ៧០៩តោន (កើនឡើងចំនួន ២០ ២៧០តោន ស្មើនឹង ៧%) ទិសដៅអាស៊ានចំនួន ៧ប្រទេស មានបរិមាណសរុបចំនួន ៦៣ ១៦៥តោន(ថយចុះចំនួន ២៣ ៧៣៤តោន ស្មើនឹង -២៧,៣១%) និងទិសដៅដទៃទៀតចំនួន២៤ប្រទេស មានបរិមាណសរុប ៨៨ ៤២២តោន (ថយចុះចំនួន ២២ ២៧៨តោន ស្មើនឹង -២០,១២%)

- ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៦២ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន10 មានរហូតដល់ ៤៥៦ ២២៣តោន (៧៣,៩៤%) និងក្រុមហ៊ុន៥២ដទៃទៀតបាននាំចេញត្រឹមតែ ១៦០ ៨៤៦តោន (២៦,០៦%)។

### ១.៥.២ ការនាំចេញស្រូវ

ក្នុងឆ្នាំ២០២១ ការនាំចេញស្រូវមានចំនួន ៣ ៥២៧ ៤១៨តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ២ ១៨៧ ១៧៧,០២តោន) ដែលមានការកើនឡើងចំនួន ១ ៣៣៨ ៦១៤តោន (៦១,១៦%) បើធៀបនឹងឆ្នាំ២០២០ ដែលមានចំនួន ២ ១៨៨ ៨០៤តោន។។

### ១.៥.៣ ការនាំចេញកសិផលផ្សេងៗ

ក្នុងឆ្នាំ២០២១ មានបរិមាណនាំចេញដោយធៀបនឹងឆ្នាំ២០២០៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៦៤៤ ៥៩១,៦៨តោន (កើនឡើងចំនួន ៨,៤៥%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ០១២ ៥៧០តោន វៀតណាមចំនួន ៥៦១ ៣០១,៥៦តោន និងប្រទេសចិនចំនួន ៧០ ៧២០,១២តោន

- ដំឡូងមីស្រស់មានចំនួន ១ ១០៤ ២២០តោន (កើនឡើងចំនួន ៥២,៦%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៨១៩ ៩៧០តោន និងប្រទេសថៃចំនួន ២៨៤ ២៥០តោន

- ម្សៅដំឡូងមីមានចំនួន ៣៥ ៨៦២,៧៤តោន (កើនឡើងចំនួន ២,៦៦%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៣៣ ១៩៨,៦០តោន ប្រទេសថៃចំនួន ១ ៣៧៥,៨០តោន ប្រទេសអ៊ីតាលីចំនួន ៦៩៤,៣៤តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ២៧២តោន សហរដ្ឋអាមេរិកចំនួន ១៧០តោន និងប្រទេសណេដឺឡែនចំនួន ១៥២តោន

- កាកសំណល់ដំឡូងមីមានចំនួន ៩ ០៥៤,៥០តោន (ថយចុះចំនួន -៣៣,០៦%) នាំចេញទៅប្រទេសចិន

- គ្រាប់ស្វាយចន្ទីមានចំនួន ៩៣៧ ៩៧៤,២៦តោន (កើនឡើងចំនួន ៣២៨,៣៤%) នាំចេញទៅប្រទេសវៀតណាមចំនួន ៩២៨ ៩២៦,២៧តោន ប្រទេសចិនចំនួន ៤ ៥៥២,៦៩តោន ប្រទេសថៃចំនួន ៤ ២៩៧,៤០តោន ប្រទេសឥណ្ឌាចំនួន ៩៨,៦០តោន ប្រទេសជប៉ុនចំនួន ៤៤,១៥តោន ប្រទេសកូរ៉េចំនួន ២១,៣៨តោន ប្រទេសអារ៉ាប់ចំនួន ១៤,៥១តោន ប្រទេសណេដឺឡែនចំនួន ៨,២១តោន ប្រទេសបង់ក្លាដែសចំនួន ៧តោន ប្រទេសឡាវចំនួន ៤តោន ប្រទេសស្វីសចំនួន ០,០២តោន ប្រទេសតូហ្គោចំនួន ០,០១តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន ប្រទេសហ្វីលីពីនចំនួន០,០០៣តោន និងប្រទេសបារាំងចំនួន០,០០២តោន

- គ្រាប់ពោតមានចំនួន ២០១ ៥៨៩,៣៤តោន (កើនឡើងចំនួន ៣,៥៨%) នាំចេញទៅប្រទេសវៀតណាមចំនួន១៥៨ ២៥០តោន ប្រទេសថៃចំនួន៤២ ៣៥០តោន កោះតៃវ៉ាន់ចំនួន ៩២៦,២៩តោន ប្រទេសបង់ក្លាដេសចំនួន ៤២,០៥តោន និងប្រទេសកូរ៉េចំនួន ២១តោន

- គ្រាប់សណ្តែកបាយមានចំនួន ២៩ ១៩២,៣៥តោន (កើនឡើងចំនួន ១៨៩,៦១%) នាំចេញទៅប្រទេសវៀតណាមចំនួន២៩ ១៧០តោន និងកោះតៃវ៉ាន់ចំនួន ២២,៣៥តោន

- គ្រាប់សណ្តែកសៀងមានចំនួន ១០៥ ៦៥៥,០៤តោន (កើនឡើងចំនួន ២៦៤,២៤%) នាំចេញទៅប្រទេសវៀតណាមចំនួន៨២ ៧០៥តោន ប្រទេសថៃចំនួន២២ ៩៥០តោន និងប្រទេសអារ៉ាប់រួមចំនួន០,០៤តោន

- ផ្លែចេកស្រស់មានចំនួន ៤២៣ ១៦៨,៩៧តោន (កើនឡើងចំនួន ២៧,០២%) នាំចេញទៅប្រទេសចិនចំនួន ៣៧៦ ៩៦១,៦០តោន ប្រទេសវៀតណាមចំនួន ៤៥ ១៩៣,៣៧តោន ប្រទេសជប៉ុនចំនួន៥៣៣,៥២តោន និងប្រទេសសិង្ហបុរីចំនួន៤៨០,៤៨តោន

- ផ្លែក្រូចថ្លុងមានចំនួន ៣៨ ៦៦៨,៤៤តោន (កើនឡើងចំនួន១២២,២៣%) នាំចេញទៅប្រទេសថៃចំនួន ៣៨ ៦០៤តោន និងប្រទេសវៀតណាមចំនួន៦៤,៤៤តោន

- ផ្លែស្វាយស្រស់មានចំនួន ២៤២ ៤៨៣,៧៦តោន (កើនឡើងចំនួន ១៤៨,៣៨%) នាំចេញទៅប្រទេសវៀតណាមចំនួន ១៩៩ ០៧៧,៣៨តោន ប្រទេសថៃចំនួន ៣៨ ៤១៩,២៨តោន ប្រទេសចិនចំនួន ៤ ៧៧១តោន ប្រទេសកូរ៉េចំនួន ១៤៩,១១តោន ទីក្រុងហុងកុងចំនួន ៥០,៧៨តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន និងប្រទេសគុយវ៉ែតចំនួន ០,០១តោន

- ដំណាប់ស្វាយមានចំនួន ១៧ ៨៧៩,៨២តោន (កើនឡើងចំនួន ១៧៩,៣០%) នាំចេញទៅប្រទេសចិនចំនួន១៤ ២៤៦,២០តោន ប្រទេសថៃចំនួន ១ ៥០១,១៣តោន ប្រទេសហ្វីលីពីនចំនួន ៩៧៥,០៨តោន ប្រទេសវៀតណាមចំនួន ៥៥៩,៣០តោន ប្រទេសជប៉ុនចំនួន ៥២៣,៧០តោន ប្រទេសរុស្ស៊ីចំនួន ២៣តោន ចក្រភពអង់គ្លេស ២១,១៤តោន ប្រទេសកូរ៉េចំនួន ១៨,៧០តោន សហរដ្ឋអាមេរិកចំនួន ៨,៥៦តោន កោះតៃវ៉ាន់ចំនួន ៣តោន និងប្រទេសកាហ្សាក់ស្ថានចំនួន ០,០៥តោន

- ទឹកស៊ីរ៉ូស្វាយមានចំនួន ៤ ៨៦៦,១៨តោន (កើនឡើងចំនួន ៣៣,២៨%) នាំចេញទៅប្រទេសហ្វីលីពីនចំនួន ៤ ៦៩៨,៦៣តោន និងប្រទេសចិនមានចំនួន ១៦៧,៥៥តោន

- ដូងប្រេងមានចំនួន ៦២ ២១៦,៦៩តោន (កើនឡើងចំនួន ១៤,២២%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ៤៨ ៩៧៦,៦៩តោន និងប្រទេសម៉ាឡេស៊ីចំនួន ១៣ ២៤០តោន

- ម្រេចមានចំនួន ២៨ ០៧៤,៧៩តោន (កើនឡើងចំនួន ៤៥២,៧២%) នាំចេញទៅប្រទេសវៀតណាមចំនួន ២៧ ១១៧,៥៤តោន ប្រទេសអាល្លឺម៉ង់ចំនួន ៦០៧,៩០តោន ប្រទេសថៃចំនួន ១៨០តោន ប្រទេសបារាំងចំនួន ៤៥,៤៥តោន ប្រទេសឥណ្ឌាចំនួន ៤២តោន ប្រទេសបែលហ្ស៊ិកចំនួន ២៥,៣៨តោន កោះតៃវ៉ាន់ចំនួន ១៥,៣៤តោន សាធារណរដ្ឋឆេកចំនួន ១២,៨៤តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន ប្រទេសជប៉ុនចំនួន ៤,០៥តោន ប្រទេសរុស្ស៊ីចំនួន ៣,៣៤តោន ប្រទេសកូរ៉េចំនួន ៣,២៩តោន ប្រទេសសិង្ហបុរីចំនួន ២,០៧តោន សហរដ្ឋអាមេរិកចំនួន ២,០២តោន ប្រទេសស្វីសចំនួន ១,៦៤តោន ប្រទេសស៊ុយអ៊ែតចំនួន ១,២៩តោន ចក្រភពអង់គ្លេសចំនួន ១,២៤តោន ប្រទេសអូស្ត្រាលីចំនួន ០,៩០តោន ប្រទេសកាណាដាចំនួន ០,៥២តោន ប្រទេសម៉ាឡេស៊ីចំនួន ០,៤០តោន ប្រទេសលីទុយអានីចំនួន ០,២៩តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,១៩តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០១តោន

- ថ្នាំជក់មានចំនួន ៤ ៥៩០,៨៥តោន (ថយចុះចំនួន -២១,១៣%) នាំចេញទៅប្រទេសវៀតណាមចំនួន ៤ ៤៨៩,៨០តោន ប្រទេសបែលហ្ស៊ិកចំនួន ៥៩,៤២តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន ប្រទេសបូស្នៀ និងហឺហ្សេហ្គោវីណាចំនួន ១,៩០តោន ប្រទេសចិនចំនួន ០,១០តោន ប្រទេសឥណ្ឌូនេស៊ីចំនួន ០,០២តោន ប្រទេសសិង្ហបុរីចំនួន ០,០១តោន និងប្រទេសអាល្លឺម៉ង់ចំនួន ០,០០១តោន

- បន្លែចម្រុះមានចំនួន ១០៤,២៥តោន (ថយចុះចំនួន -១,១៥%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ៩៨ ៣៨៧,១២តោន (កើនឡើងចំនួន ៣៩,៤៦%) នាំចេញទៅប្រទេសថៃចំនួន ៩៨ ៣៨៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន

- ម្ទេសក្រៀមមានចំនួន ២ ១៦០,២៣តោន (កើនឡើងចំនួន ២០,០១%) នាំចេញទៅប្រទេសថៃចំនួន ២ ១៦០តោន ប្រទេសបែលហ្ស៊ិកចំនួន ០,២១តោន ប្រទេសកូរ៉េចំនួន ០,០១តោន និងប្រទេសកាណាដា ចំនួន ០,០១តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៨ ៥៤៦ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩៤ ៤៥៤ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦១ ១៦០ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១៤ ៣១៩ហ.ត ស្មើនឹង៧៨% និងផ្ទៃដីថែទាំចំនួន ៨៩ ៨៤១ហ.ត ស្មើនឹង២២%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូរយៈពេល១១ខែ ឆ្នាំ២០២១ មានចំនួន ៣១៩ ៥០៩តោន កើនឡើងចំនួន ២៨ ១៩១តោន ស្មើនឹង១០% ធៀបរយៈពេល១១ខែ ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូរយៈពេល១១ខែ ឆ្នាំ២០២១ សម្រេចបានចំនួន ៦ ០៤៨ម៣។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូរយៈពេល១១ខែ ឆ្នាំ២០២១ មានចំនួន ៣១២ ៨១២តោន បានកើនឡើងចំនួន ២៦ ៩៥៥តោន ស្មើនឹង៩% ធៀបរយៈពេល១១ខែ ឆ្នាំ២០២០

- បរិមាណបញ្ចេញលក់ឈើកៅស៊ូរយៈពេល១១ខែ ឆ្នាំ២០២១ សម្រេចបានចំនួន៥ ៨៣៨ម៣។

២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែវិច្ឆិកា គឺ១ ៦៦៩ដុល្លារ/តោន បានកើនឡើងចំនួន ២៣ដុល្លារ/តោន ស្មើនឹង១,៤% ធៀបនឹងខែមុន និងបានកើនឡើងចំនួន ១៥២ដុល្លារ/តោន ស្មើនឹង១០% ធៀបខែវិច្ឆិកា ឆ្នាំ២០២០

- តម្លៃលក់ជ័រកៅស៊ូមធ្យមរយៈពេល១១ខែ ឆ្នាំ២០២១ គឺ១ ៦៦៤ដុល្លារ/តោន បានកើនឡើងចំនួន ៣២៣ដុល្លារ/តោន ស្មើនឹង២៤,១% ធៀបរយៈពេល១១ខែ ឆ្នាំ២០២០

- តម្លៃលក់ឈើកៅស៊ូមធ្យមក្នុងខែវិច្ឆិកា គឺ២៦២,៩១ដុល្លារ/ម៣

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅនឹងចម្ការក្នុងខែវិច្ឆិកា គឺទឹកជ័រ (DRC ១០០%) មានការប្រែប្រួលពី ៥ ៨០០៛/គ.ក្រ ដល់ ៦ ២០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៣០០៛/គ.ក្រ ដល់ ៣ ៣០០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២១ ចំនួន ៣០ផ្ទាំង និងរូបភាពផ្កាយរណប Sentinel-2 ចំនួន ២៥ផ្ទាំង និងពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១

- ចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៧កន្លែងមានផ្ទៃដីសរុបទំហំ ៣ ៦៧៣,៧៨ហ.ត

- ចុះផ្សព្វផ្សាយស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើចំនួន ៦កន្លែង គឺ សហគមន៍ព្រៃឈើជាវៅ សហគមន៍ព្រៃឈើត្រពាំងត្រាច សហគមន៍ព្រៃឈើអណ្តូងច្រុះ សហគមន៍ព្រៃឈើភូមិប្រស្និប សហគមន៍ព្រៃឈើភូមិសារអង និងសហគមន៍ព្រៃឈើភូមិត្រពាំងអំពិលក្នុងខេត្តកំពង់ឆ្នាំង

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ១១០គ្រឿង និងយានយន្តចំនួន ១៤៥គ្រឿងជូនក្រុមហ៊ុនចំនួន ៩ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៩ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ៨នាក់ដែលមានឈើហ៊ុបមូលចំនួន ២១ ៦៥០ម៣ ឈើអារចំនួន ១ ៥២៧ម៣ ឈើជ្រុងចំនួន ៤ម៣ កូនឈើចំនួន ២៥២ ២៩៥ដើម អុសចម្រុះចំនួន ១៩០ ៥៩៧ស្ទេរ ឫស្សីចំនួន ៩៦តោន ធ្យូងចំនួន ៣ ០០០គ.ក្រ និងជ័រទឹកចំនួន ៦២៨តោន និងផលអនុផលព្រៃឈើមួយចំនួនទៀត។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះពិនិត្យ និងប្រមូលម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៧គ្រឿងដែលបានបំពាក់ដើម្បីថត និងតាមដានវត្តមានសត្វព្រៃនៅក្នុងសហគមន៍ព្រៃឈើប្រាំបីមុំ ដើម្បីប្រមូលទិន្នន័យ និងជាតុចូលបន្ថែមសម្រាប់សម្រួលដល់ការចងក្រងអត្ថបទចុះផ្សាយស្តីពីការសិក្សាស្រាវជ្រាវពីជីវចម្រុះនៅក្នុងតំបន់សហគមន៍ព្រៃឈើប្រាំបីមុំ ខេត្តកំពង់ស្ពឺ និងម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ១២គ្រឿងបំពាក់សម្រាប់តាមដានវត្តមាន និងកត្តាគំរាមកំហែងសត្វព្រៃ និងដំរីព្រៃនៅតាមតំបន់ជួរភ្នំក្រវាញខេត្តកោះកុង

- សិក្សាស្រាវជ្រាវ អង្កេតតាមដាន ប្រមូលទិន្នន័យវត្តមានសត្វព្រៃ និងដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ១២គ្រឿង ដើម្បីថតចាប់យករូបភាពសត្វព្រៃនៅក្នុងតំបន់ព្រៃឈើសហគមន៍វាលកន្សែង ខេត្តក្រចេះ

- ចុះប្រមូលលាមកសត្វដំរីសរុបចំនួន ១៤៩សំណាកក្នុងដែនជម្រកសត្វព្រៃ (ព្រៃឡង់) ស្រុកសៀមបូក ខេត្តស្ទឹងត្រែង និងដែនជម្រកសត្វព្រៃឆែប និងដែនជម្រសត្វព្រៃព្រះរការក្នុងស្រុកជាំក្សាន្ត និងស្រុកឆែប ខេត្តព្រះវិហារ

- ចុះពិនិត្យពីស្ថានភាព និងការងារអភិរក្សសត្វកន្ធាយក្បាលកង្កែបតាមដងទន្លេមេគង្គខេត្តស្ទឹងត្រែង និងខេត្តក្រចេះចំនួន ៦៥សំបុក ស្មើនឹង១ ៣០០កូន

- ចុះសិក្សាកំណត់តំបន់សក្តានុពលទេសចរណ៍ធម្មជាតិចំនួន ៣លើក ដើម្បីពិភាក្សាពីការកំណត់តំបន់សក្តានុពលនៅជួរភ្នំដំរីរមៀលស្រុកត្រាំកក់ ខេត្តតាកែវដោយសហការជាមួយខណ្ឌរដ្ឋបាលព្រៃឈើតាកែវ និងអាជ្ញាធរមូលដ្ឋាន

- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១២១ច្បាប់ ក្នុងនោះ ១០៨ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង១៣ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកោះកុង កែប ពោធិ៍សាត់ បាត់ដំបង កំពត តាកែវ កណ្តាល សៀមរាប បន្ទាយមានជ័យ ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ និងខេត្តមណ្ឌលគិរី។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំចំនួន២ទីតាំង មានសត្វ

ស្វាក្តាមសរុបចំនួន ១០៥ ៦៣៦ក្បាល ក្នុងនោះ កូនកើតក្នុងខែរយៈពេល១ឆ្នាំមានចំនួន ៦៩ ១៣៨ក្បាលដឹកជញ្ជូនក្នុងស្រុកចំនួន ៤ ៤២០ក្បាល និងដឹកជញ្ជូនសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ២៤ ២០៥ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅបាននិងកំពុងថែរក្សាសត្វព្រៃចំនួន ១ ៦៧៥ក្បាល (បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ៩៤៤ក្បាល ព្យាបាលចំនួន ៣៩០ក្បាល

- ក្រុមល្បាតសហគមន៍ចំនួន ២៦នាក់បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- អង្កេតតាមដានប្រចាំឆ្នាំនៅស្ទឹងខៀវ ស្ទឹងអារ៉ែង ស្ទឹងដាច់ ខេត្តកោះកុង និងបឹងវាលវែង ខេត្តពោធិ៍សាត់ ដោយរកឃើញក្រពើភ្នំចំនួន ៩ក្បាល លាមកក្រពើចំនួន ១១២ដុំ និងស្នាមដានចំនួន ១៥កន្លែង ព្រមទាំងស្រាវជ្រាវរកឃើញក្រពើចំនួន ១៤ក្បាល និងសំបុកចំនួន១មានពងចំនួន ២០គ្រាប់

- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ១៨គីឡូម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ៤៥ហ.តនៅក្នុងតំបន់សួនសត្វ។

## ៣.៤ ការងារដាំដើមឈើ

- ជីកប្រឡាយការពារចម្ការគ្រញូងនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអន្លង់ថ្មខេត្តកំពង់ធំប្រវែង៨ ០០០ម៉ែត្រ

- បង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើសែនមនោរម្យនៅក្នុងខេត្តមណ្ឌលគិរីលើផ្ទៃដីទំហំ ១០០ហ.ត២៦៣ និងចុះសិក្សាទីតាំងបង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើលើផ្ទៃដីសរុបទំហំ ២២ ៣០៨ហ.ត០៦៧៦ នៅខេត្តប៉ៃលិន កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ៨២២ហ.ត ក្នុងនោះ ចម្ការពូជឈើទំហំ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ៤៤ហ.ត ចម្ការឈើដាំទំហំ៦៥៤ហ.ត និងចម្ការរុក្ខទិវា៩ កក្កដាទំហំ៣០ហ.ត នៅក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ដាំឈើជាចម្ការថ្មីលើផ្ទៃដីទំហំ៧ ៥៩៩ហ.ត៥ ក្នុងនោះ ដាំឈើដោយរដ្ឋមានទំហំ១៤០ហ.ត និងដាំឈើដោយក្រុមហ៊ុនឯកជនដៃគូសហការ និងបុគ្គលឯកជនលក្ខណៈគ្រួសារទំហំ៧ ៤៥៩ហ.ត៥

- បណ្តុះកូនឈើគ្រប់ប្រភេទសរុបចំនួន ៥៧២ ៥២៩ដើម (ខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៣៧៣ ៧៥៤ដើម និងថ្នាលបណ្តុះកូនឈើចំនួន៦ចំនួន ១៩៨ ៧៧៥ដើម) និងបានចែកចាយកូនឈើសម្រាប់ដាំអាស្រ័យផលសរុបចំនួន ៣៧៣ ៧៤៦ដើម (ខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ១៧៤ ៩៧១ដើម និងថ្នាលបណ្តុះកូនឈើចំនួន៦ចំនួន ១៩៨ ៧៧៥ដើម)។

## ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៧៧៧ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូតមានឈើអារចំនួន ១ ១៩២ម៣ ឈើមូល-ជ្រុងចំនួន ៣២ម៣ ឈើអារគ្រញូង ០,៤៩៥ម៣ និង៨៦០គ.ក្រ និងផ្ទៃដីព្រៃឈើបានកាប់រានទំហំ៣ ៥៦៥ហ.ត

- វត្ថុតាងសត្វព្រៃបានចាប់ឃាត់មានចំនួន ១ ៩៨២ក្បាល និង៥៤១គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារមួយចំនួនទៀត

- វត្ថុតាងសត្វព្រៃ និងសំណាកសត្វព្រៃប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ២២៨ករណី ធ្វើកិច្ចសន្យាចំនួន ៣៧ករណី និងធ្វើដកហូតចំនួន ៤៨ករណី។

## ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ៩កន្លែងនៅខេត្តបាត់ដំបង មណ្ឌលគិរី ព្រៃវែង កំពង់ស្ពឺ កណ្តាល ព្រះវិហារ ក្រចេះ និងខេត្តបន្ទាយមានជ័យ២កន្លែង ព្រមទាំងពន្យារសុពលភាពចំនួន ៩កន្លែងនៅក្នុងរាជធានីភ្នំពេញ ខេត្តស្វាយរៀង ព្រៃវែង រតនគិរី កណ្តាល កំពង់ចាម ២កន្លែង និងខេត្តកំពង់ធំ២កន្លែង

- ពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៥កន្លែងនៅខេត្តព្រះវិហារ តាកែវ ស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ២កន្លែង ពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ រោងសិប្បកម្មកែច្នៃចិញ្ច្រាំកម្ទេចឈើដាំ និងរោងចក្រផលិតក្តារបន្ទះចំនួន ១៥កន្លែងនៅរាជធានីភ្នំពេញ២កន្លែង ក្រចេះ បន្ទាយមានជ័យ ព្រះវិហារ កំពង់ស្ពឺ កណ្តាល ព្រៃវែង បាត់ដំបង២កន្លែង មណ្ឌលគិរី៣កន្លែង និងខេត្តស្ទឹងត្រែង២កន្លែង

- ក្រុមហ៊ុនចំនួន៨នាំចេញផលិតផលរានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសមានចំនួន ១ ២៧៥ម៣ ជ័រទឹកចំនួន ៣៦២តោន និងចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ១០ ៦៤០តោន

- ក្រុមហ៊ុនចំនួន៣នាំចូលឈើកែច្នៃមានបរិមាណចំនួន ២ ០៨៥ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១០មានឈើកែច្នៃចំនួន ១ ៤១៨ម៣ ចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ១១ ០០០តោន ឫស្សីកែច្នៃចំនួន ៧៩តោន និងជ័រទឹកចំនួន ៣៨៤តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន៤មានបរិមាណឈើកែច្នៃ (MDF, Wood Panel, Dark Red Meranti, Chanfuta និងឈើស្រស់) សរុបចំនួន ២ ៦០៦ម៣។

**៣.៧ ការងារចំណូលព្រៃឈើ**

- ប្រមូលចំណូលសរុប ៦ ៨៨៤ ៤៦៨ ៤១៧រៀល និង២ ៦០៨ ៩៩៣,៧២ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។ កំពុងរៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ការសាងសង់ឡជីវឧស្ម័នក្នុងឆ្នាំ២០២១នេះ ការសាងសង់ឡក្នុងកម្មវិធី NBP សាងសង់ឡបានចំនួន ៤៩៩ឡ ក្នុងខេត្តគោលដៅចំនួន ១៤ខេត្ត និងគម្រោងចិនសាងសង់ឡ៧ឡ ក្នុងខេត្តព្រះវិហារ៥ឡ និងខេត្តពោធិ៍សាត់២ឡ ។

**៤.២ ការងារសុខភាពសត្វ**

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១៦៩ករណី ក្នុងនោះ មានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន ១១៤ករណី និងមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ (បទល្មើស) ចំនួន ៥៥ករណី។ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៩៣ ៤១៤លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះផ្សព្វផ្សាយស្តីពី៖ ជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៧ ណែនាំកសិករនិងអ្នកពាក់ព័ន្ធនឹងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន២ បច្ចេកទេសចិញ្ចឹមសត្វនិងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន២ ជំងឺដុំពកលើស្បែកគោក្របីនៅតាមខេត្តចំនួន១

- ចូលរួមសហការរៀបចំសៀវភៅចិញ្ចឹមមាន់មេពូជជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចូលរួមសហការរៀបចំឯកសារផ្សព្វផ្សាយស្តីពីជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមការគាំទ្ររបស់អង្គការ FAO ចូលរួមរៀបចំវេទិកាផ្សព្វផ្សាយស្តីពីជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅតាមខេត្តចំនួន២ ដោយសហការជាមួយអង្គការ FAO។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ

- រៀបចំលិខិតបទដ្ឋានគតិយុត្តទំនាក់ទំនងការងារវិមជ្ឈការ និងវិសហមជ្ឈការ ចូលរួមពិនិត្យ និងផ្តល់យោបល់លើសំណើបញ្ជូនលិខិតបទដ្ឋានគតិយុត្ត និងឯកសារផ្សព្វផ្សាយបច្ចេកទេសរបស់នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម ពិនិត្យ និងផ្តល់យោបល់លើសំណើបញ្ជូនលិខិតបទដ្ឋានគតិយុត្ត ក្រោមការធ្វើពាណិជ្ជកម្មក្រោមក្របខ័ណ្ឌអង្គការ WTO

- ចុះពិនិត្យ និងតាមដានការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន៦ ចុះប្រជុំផ្សព្វផ្សាយច្បាប់ និងកម្រងលិខិតបទដ្ឋានគតិយុត្តវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន២ ផ្សព្វផ្សាយ និងផ្តល់ជូននូវឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ រួមមានៈ ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ អនុក្រឹត្យ និងប្រកាសពាក់ព័ន្ធទាំងភាសាខ្មែរ និងភាសាអង់គ្លេសជូនដល់ក្រុមការងារមកពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ចុះសម្របសម្រួលដោះស្រាយពាក្យបណ្តឹងបានចំនួន ២ករណី នៅខេត្តកំពង់ធំ និងខេត្តកំពង់ចាម។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៩ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ២២ ១៧៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។ ក្នុងឆ្នាំ២០២១នេះ ជំងឺផ្តាសាយបក្សីមានផ្ទុះចំនួន១កន្លែង នៅភូមិព្រៃកតាច្រែង ឃុំព្រៃកនរិទ្ធ ស្រុកឯកភ្នំ ខេត្តបាត់ដំបង។ ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) បានរកឃើញតាមរយៈការលួចនាំជ្រូកចូលពីប្រទេសថៃ ចំនួន២ករណីនៅខេត្តបន្ទាយមានជ័យ និងត្រូវបានមន្ត្រីជំនាញសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធសម្រេចដុតកម្ទេចចោល តាមវិធានការបសុព្យាបាល និងជំងឺដុំពកស្បែកគោ ក្របី (LSD) សរុបចំនួន៧៦កន្លែង ក្នុងនោះ ៩កន្លែងក្នុងខេត្តកណ្តាល ១០កន្លែងក្នុងខេត្តកំពង់ឆ្នាំង ១កន្លែង ក្នុងខេត្តកំពង់ស្ពឺ ១០កន្លែងក្នុងខេត្តព្រៃវែង ១៩កន្លែងក្នុងខេត្តសៀមរាប ៥កន្លែងក្នុងខេត្តស្ទឹងត្រែង ៦កន្លែងក្នុងខេត្តក្រចេះ ៨កន្លែងក្នុងខេត្តបន្ទាយមានជ័យ ៦កន្លែងក្នុងខេត្តពោធិ៍សាត់ ១កន្លែងក្នុងខេត្តតាកែវ និង ១កន្លែងក្នុងខេត្តព្រះវិហារ បណ្តាលឲ្យសត្វឈឺសរុបចំនួន ៦ ៣៨១ក្បាល និងងាប់គោ៨៥ក្បាល។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបានចំនួន ៨ ៧០០តោន ស្មើនឹង៧៩,០៩% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ១ ២០០តោន

- នេសាទគ្រួសារតាមដែននេសាទបានចំនួន ២៣៥ ៨៥០តោន ស្មើនឹង៧៨,៦២% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ៣២ ១៥០តោន

- នេសាទគ្រួសារតាមវាលស្រែបានចំនួន ១៣៨ ៥០០តោន ស្មើនឹង៩៨,៩៣% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ កើនឡើងចំនួន ៣ ២០០តោន។

#### ៥.១.២ នេសាទសមុទ្រ

បានចំនួន ១២៥ ០០០តោន ស្មើនឹង៩៦,១៥% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ កើនឡើងចំនួន ២ ៣០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាបានចំនួន ៣៤៨ ៣៥០តោន ស្មើនឹង៧២,៤២% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ៥២ ០៥០តោន

- ការចិញ្ចឹមក្រពើបានចំនួន ២៩២ ១០០ក្បាល ស្មើនឹង៨៨,៥២% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ២១ ០០០ក្បាល

- ការភ្ញាស់កូនត្រីពូជបានចំនួន ៣២៤ ១០៦ ០០០កូន ស្មើនឹង១២០,០៤% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ៨៩ ១០៦ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបបានចំនួន ៥១ ៦៥០តោន ស្មើនឹង៦៤,៥៦% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ១០ ៣៥០តោន

- ផលនេសាទសមុទ្របានចំនួន ១១ ៦៦០តោន ស្មើនឹង៩៧,១៧% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ កើនឡើងចំនួន ២៦០តោន

- ការផលិតទឹកត្រីបានចំនួន ៥១ ៣០០ ០០០លីត្រ ស្មើនឹង៩៣,២៧% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ១ ៧០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២ ៩៩៩ករណី ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ១៦៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២ ៧៦០ករណី និងសមុទ្រចំនួន ២៣៩ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ២ ៩១៦តោន ស្មើនឹង៣៦,៤៥% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបឆ្នាំ២០២០ កើនឡើងចំនួន ៩៧១តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ១៥០តោន ស្មើនឹង៧,៥០% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៨៤តោន។

### ៥.៦ ការប្រមូលចំណូលថវិកាសេវាជលផល

- ចំណូលចំនួន ៥៨១ ៧១២ ៩៧៦រៀល ស្មើនឹង១៦២,២២% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបឆ្នាំ២០២០ ថយចុះចំនួន ៩៧៨ ០៧២ ៧៨៤រៀល។

## ៦ ផ្នែកអធិការដ្ឋាន

- ចុះត្រួតពិនិត្យលើការងារអនុវត្តតួនាទីភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ និងមេគង្គ

- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តកណ្ដាល ត្បូងឃ្មុំ តាកែវ ព្រៃវែង កំពត ស្វាយរៀង រាជធានីភ្នំពេញ បាត់ដំបង និងខេត្តបន្ទាយមានជ័យ

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែរក្រសួងបានណែនាំឱ្យកែលម្អកន្លងមក

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលជលផលស្វាយរៀង នៅខេត្តស្វាយរៀង

- ចុះស្រាវជ្រាវលើការដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វនាំចូលពីបរទេសនៅខេត្តត្បូងឃ្មុំ

- ការទទួលពាក្យបណ្ដឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតចំនួន ៥ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១ ១២៨ករណី លើវិស័យព្រៃឈើ ២៤១ករណី ជលផល២៦៤ករណី សុខភាពសត្វនិងផលិតកម្មសត្វ១៤៧ករណី កៅស៊ូ១២ករណី កសិ-ឧស្សាហកម្ម ៥ករណី ក្សេត្រសាស្ត្រ៦ករណី នីតិកម្ម៥ករណី និងវិស័យផ្សេងៗ៤៤៨ករណី

- ចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៤៩ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧ ៨១៨ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣ ០៦៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣ ៤៧៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ២៧៦ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១២ ២៨៨ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ៤៦២ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២៦១ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស ខែវិច្ឆិកា និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្ដាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការរៀបចំកិច្ចប្រជុំ ការទទួលភ្ញៀវ ពិធីចុះហត្ថលេខា និងសិក្ខាសាលាមានចំនួន ១៤៣លើក មានសមាជិកចូលរួមចំនួន ៣ ៨៥៨នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៩៤០នាក់ (ស្រី១ ៤៦៩នាក់ ស្មើនឹង២៤,៧៣%) រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩៨៦នាក់ (ស្រី៨៥៩នាក់ ស្មើនឹង២៨,៧៦%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៥៤នាក់ (ស្រី៦១០នាក់ ស្មើនឹង២០,៦៤%)
- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៩៣នាក់ (ស្រី៣៦នាក់)
- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ២១នាក់ (ស្រី៣នាក់)

- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ១៣នាក់ (ស្រី១នាក់) ផ្ទេរចូលក្នុងក្រសួង ចំនួន១១នាក់ (ស្រី៤នាក់) និងផ្ទេរផ្ទៃក្នុងក្រសួងចំនួន ៦២នាក់ (ស្រី៧នាក់)
- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៥៨នាក់ (ស្រី៣៩នាក់)
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ចំនួន ២៤នាក់ (ស្រី១២នាក់)
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលបម្រើការងារវិញចំនួន ២១នាក់ (ស្រី៣នាក់)
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ២៦នាក់ (ស្រី៨នាក់)
- រៀបចំការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១ ៥១៧នាក់ (ស្រី៤១៤នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ១ ៤៥៣នាក់ (ស្រី៣៩៨នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យមតាមរយៈប្រព័ន្ធ online ចំនួន ៦៤នាក់ (ស្រី១៦នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- រៀបចំផ្តល់ធាតុចូលរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០១៩-២០២៣ ដោយបានបង្ហាញនូវលទ្ធផលនៃការអនុវត្តវិស័យកសិកម្មក្នុងរយៈពេល២ឆ្នាំកន្លះ
- រៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជាឆ្នាំ២០២១-២០៣០ និងបានកែសម្រួលតាមការផ្តល់យោបល់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបានបញ្ជូនទៅគណៈកម្មាធិការវិញដើម្បីពិនិត្យ និងផ្តល់យោបល់បន្ថែមចុងក្រោយមុននឹងដាក់ជូនទៅគណៈរដ្ឋមន្ត្រី
- រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល២០២២-២០២៤
- រៀបទិន្នន័យសម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥
- ពិនិត្យ និងសម្របសម្រួលលើការរៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័នឆ្នាំ២០២១-២០៣០
- រៀបចំពិនិត្យ និងបញ្ជូនវិធានការគោលនយោបាយជំរុញវារីវប្បកម្មកម្ពុជាឆ្នាំ២០២១-២០២៣
- រៀបចំសំណើសុំធ្វើការកែសម្រួលលើសេចក្តីព្រាងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (IDP) ឆ្នាំ២០១៥-២០២៥ និងរៀបចំផែនការថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០២២
- ប្រមូលចងក្រងព័ត៌មានទិន្នន័យឯកសារបញ្ជីដីឯកជនរបស់រដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចនៃគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្នុងប្រព័ន្ធកុំព្យូទ័រចំនួន ១៥៥គម្រោង លើគម្រោងសរុបចំនួន ២២៩គម្រោង
- អនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាលបញ្ចេញដោះដូរពូជស្រូវជលសារចំនួន ៦ ៩៦៩គ.ក្រ
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិស្រូវពូជនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ចាម ស្វាយរៀង មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តកំពង់ស្ពឺ
- ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងចុងក្រោយផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែបឆ្នាំ២០២១-២០៣៥
- រៀបចំលិខិតសុំផ្តល់ធាតុចូលលើសេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២១-២០៣០ រៀបចំពិនិត្យ និងសម្រេចស្តីពីសំណើសុំទិន្នន័យពាក់ព័ន្ធសម្រាប់ជាធាតុចូលក្នុងការវាយតម្លៃសេដ្ឋកិច្ចពាក់កណ្តាលឆ្នាំ២០២១ ដើម្បីគោរពគោលការណ៍ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា
- ធ្វើការណែនាំ និងធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំង និងស្រូវវស្សាឆ្នាំ២០២១-២០២២ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្ត និងស្រុក
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍ជារៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥
- ចុះតាមដានការគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាននៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ កំពង់ស្ពឺ ព្រៃវែង កំពង់ធំ និងខេត្តកំពង់ចាម។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- ចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៦៨ ៨៩៣,៩លានរៀល ស្មើនឹង១៩៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ

- អនុវត្តចំណាយសរុបបានចំនួន ១១៩ ១១៣,២លានរៀល ស្មើនឹង៧២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ស្មើនឹង៨០% ធៀបនឹងឥណទានក្រោយវិចារណកម្ម

- ក្នុងឆ្នាំ២០២១នេះ ចំនួនគណនីធនាគារ គឺមានចំនួន ៣៧គណនី ដោយថយចុះ២គណនី ធៀបនឹងឆ្នាំ២០២០

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៣៩ក្រុមហ៊ុន សរុបទឹកប្រាក់ចំនួន ៥ ៩៣៨ ០៨១ ៧៨២រៀល

- ចុះបំពេញបេសកកម្មនៅទីតាំងរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ៥៩ក្រុមហ៊ុនក្នុងខេត្តគោលដៅចំនួន១០ខេត្ត

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០២០ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១៧ខេត្ត សម្រេចបានទៅតាមទិសដៅស្របតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២១

- ចូលរួមសហការចុះពិនិត្យបញ្ជីចំណូលសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ នៅគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំង៥ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះរៀបចំបិទ និងបើកបញ្ជីប្រគល់ ទទួលថវិកា និងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការផ្ទេរតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំអង្គភាពចាស់ដែលត្រូវផ្ទេរចេញដោយការដាក់ឱ្យចូលនិវត្តន៍ ឬត្រូវបានដំឡើងតួនាទីឱ្យទៅទទួលខុសត្រូវនៅអង្គភាពថ្មីចំនួន ៥អង្គភាព រួមមាន វិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា រដ្ឋបាលជលផល វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

- ចូលរួមនិងជួយរៀបចំឯកសារអង្គភាពលទ្ធកម្មលើដំណើរការអនុវត្តកិច្ចលទ្ធកម្មសម្រាប់បម្រើឱ្យការផ្គត់ផ្គង់ទំនិញ ការងារសាងសង់ ជួសជុលសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាជូនអង្គភាពនានាក្រោមឱវាទក្រសួងសរុបចំនួន២៦ គម្រោងមានទឹកប្រាក់សរុបចំនួន ២៣ ៩១៥ ០០៦ ០០០រៀល

- ចូលរួមប្រជុំពិនិត្យ សិក្សា និងវាយតម្លៃមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី ឧត្តរមានជ័យ ត្បូងឃ្មុំ ក្រចេះ កំពង់ធំ កំពត និងខេត្តកំពង់ស្ពឺដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

- ចូលរួមដេញថ្លៃ និងពិគ្រោះថ្លៃផលឈើដាំនៅសង្កាត់រដ្ឋបាលព្រៃឈើឆ្លូង ផ្នែករដ្ឋបាលព្រៃឈើឆ្លូងនៃខណ្ឌរដ្ឋបាលព្រៃឈើក្រចេះ

- ចូលរួមប្រជុំ ពិនិត្យ និងវាយតម្លៃលក់ផលឈើដាំដែលមានក្នុងទីតាំងដីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង

- ចូលរួមចុះពិនិត្យផ្ទៀងផ្ទាត់តារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ស្ពឺ ស្វាយរៀង ព្រៃវែង តាកែវ កំពង់ឆ្នាំង ក្រចេះ ព្រះសីហនុ និងខេត្តកំពត

- ចូលរួមដេញថ្លៃលក់ជាសាធារណៈនូវទ្រព្យសម្បត្តិចាស់ទ្រុឌទ្រោមខូចប្រើប្រាស់លែងកើតដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី។

**១១ ផ្នែកសវនកម្មផ្ទៃក្នុង**

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០២០
- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង២០២១-២០២៣
- រៀបចំផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២២
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤
- រៀបចំផែនការរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២២
- រៀបចំផែនការវិចារណកម្មចំណាយឆ្នាំ២០២១ និងផែនការថវិកាឆ្នាំ២០២២
- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស M2 ប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១
- ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ចំនួន ២១សវនដ្ឋាន ស្មើនឹង៥២,៥០% នៃផែនការ៤០សវនដ្ឋាន គឺមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម កែប តាកែវ រាជធានីភ្នំពេញ ត្បូងឃ្មុំ កោះកុង កំពត ពោធិ៍សាត់ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា រដ្ឋបាលព្រៃឈើ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម វិទ្យាស្ថានស្រាវជ្រាវ

កៅស៊ូកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូ នាយកដ្ឋាននីតិកម្មកសិកម្ម គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប (TSSD-AF) គម្រោងការគ្រប់គ្រងធនធានជលផលភូមិភាគឥសាន្ត គម្រោងកែលម្អការអប់រំឧត្តមសិក្សា គម្រោងពិពិធកម្មកសិកម្មកម្ពុជា កម្មវិធីផ្សព្វផ្សាយបច្ចេកទេសថ្មីធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ។

**១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ**

- ទទួលជួបពិភាក្សាការងារជាមួយស្ថានទូត៣លើក
- ចូលរួមកិច្ចប្រជុំ២លើក និងទិវា១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ចូលរួមកិច្ចប្រជុំ២លើក (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- ចូលរួមសិក្ខាសាលា (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ២លើកក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- សម្របសម្រួលកិច្ចប្រជុំ៧លើក ទិវា២លើកលើការងារក្នុងប្រទេស
- សម្របសម្រួលលើសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការអាស៊ានលើការងារវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍
- សម្របសម្រួលលើសំណើសុំផ្តល់លិខិតតុបករណ៍បញ្ជាក់ការទទួលស្គាល់ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូក៣ស្តីពីការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់
- សម្របសម្រួលកិច្ចការងារជាមួយអង្គការ Oxfam ស្តីពីកម្មវិធីអភិបាលកិច្ចធនធានធម្មជាតិ និងកម្មវិធីសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន
- សម្របសម្រួលកិច្ចការងារជាមួយអង្គការគោសប្បុរសស្តីពីកម្មវិធីសង្គ្រោះ និងថែរក្សាសត្វព្រៃ។

**១៣ ផ្នែកនីតិកម្មកសិកម្ម**

**១៣.១ ការិយាល័យអាជីវកម្មជី ថ្នាំកសិកម្ម**

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៨១ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៥២ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧៤ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧៧ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ និងវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ១៩ក្រុមហ៊ុន។

**១៣.២ ការិយាល័យមន្ទីរពិសោធន៍**

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨៧ក្រុមហ៊ុន សរុបចំនួន ៤៩៣សំណាក។

**១៣.៣ ការិយាល័យអភិវឌ្ឍបទដ្ឋានគតិយុត្ត**

- ពិនិត្យលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗក្នុងក្រសួងចំនួន ១០ករណី
- ពិនិត្យលើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗក្រៅក្រសួងចំនួន ២ករណី
- ពិនិត្យ និងផ្តល់មតិលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗ ១៣ករណី
- ពិនិត្យ និងផ្តល់មតិលើសំណើសុំគោលការណ៍ផ្សព្វផ្សាយធ្វើសិក្ខាសាលាដល់អាជីវករថ្នាំកសិកម្ម និងជីកសិកម្ម និងកសិករអំពីរបៀបប្រើប្រាស់ផលិតផលថ្នាំកសិកម្ម និងជីកសិកម្ម ប្រកបដោយសុវត្ថិភាពខ្ពស់តាមរយៈស្ថានីយវិទ្យុ និងទូរទស្សន៍នៅតាមបណ្តារាជធានី-ខេត្តចំនួន ៥ក្រុមហ៊ុន។

**១៣.៤ ការិយាល័យអនុវត្តច្បាប់**

- ចុះពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨៧ក្រុមហ៊ុន ស្មើនឹង១១៧លើក
- ចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ១៦ខេត្ត លើដេប៉ូចំនួន ៧០ដេប៉ូ មធ្យោបាយដឹកជញ្ជូនចំនួន១ដោយសម្រេចពិន័យអន្តរការណ៍ចំនួន ១៥ករណី និងពិន័យក្រុមហ៊ុនពុំបានប្រកាសប្រទិវេទន៍ចំនួន ៥ក្រុមហ៊ុន។

**១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម**

- ដកស្រង់ព័ត៌មានកសិកម្មប្រចាំថ្ងៃចេញពីបណ្តាញផ្សព្វផ្សាយសារព័ត៌មានសរុបចំនួន ២ ៦៣៤ព័ត៌មាន
- ថែទាំគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ដាក់ឲ្យដំណើរការប្រើប្រាស់អ៊ីម៉ែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ថ្នាក់ដឹកនាំប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ

- បង្កើត Sub Domain (dal.maff.gov.kh) របស់នាយកដ្ឋាននីតិកម្មកសិកម្មសម្រាប់ភ្ជាប់ទៅកាន់ប្រព័ន្ធ QR Code នៃព័ត៌មានផលិតផលថ្នាំកសិកម្មបានចុះបញ្ជី

- តាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រសរុបចំនួនផុស ៤ ១៦១ព័ត៌មាន

- រៀបចំផ្ទៃដីប្រមូលផល និងបរិមាណផលដំណាំសាកវប្បកម្មរយៈពេលវែងប្រចាំឆ្នាំ២០២០ សម្រាប់ទិន្នន័យដំណាំកសិកម្មរាជធានី-ខេត្ត រួមមានៈ ដំណាំចេកជម្មតា ចេកអំបូងលឿង ស្វាយ ល្មុត ពុទ្រា ល្ហុង ម្នាស់ មៀន តាំងែន ក្រូចពោធិ៍សាត់ ក្រូចថ្លុង ខ្នុរ ទុរេន ស្រកានាគ ត្របែក ទៀប ក្រូចឆ្មារ ប័រ សាម៉ាវ ផាសិន និងបរិមាណផលដំណាំឧស្សាហកម្មរយៈពេលវែងសម្រាប់ទិន្នន័យដំណាំកសិកម្មរាជធានី-ខេត្ត រួមមានៈ ដំណាំម្រេច ដូង ដូងប្រេង កាហ្វេ និងដំណាំស្វាយចន្ទី

- ចុះថតផលិតវីដេអូស្តីពីបទពិសោធន៍ជោគជ័យរបស់កសិករដាំទុរេនក្នុងខេត្តមណ្ឌលគិរី

- ទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ២៤៩ក្បាល/ច្បាប់

- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកមានអ្នកចូលអានចំនួន ១៣៥ ៦៥៩ដង/នាក់

- បញ្ចូលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម និងអត្ថបទផ្សេងៗសរុបចំនួន ១៤៨ក្បាល/ច្បាប់ ព្រឹត្តិបត្រព័ត៌មានចំនួន ៦៩ និងវីដេអូបច្ចេកទេសចំនួន ៥១វីដេអូ លើគេហទំព័របណ្ណាល័យអេឡិចត្រូនិក។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- នាទីកសិកម្មប្រចាំសប្តាហ៍ផលិតវីដេអូបទយកការណ៍បច្ចេកទេសកសិកម្មចំនួន ១៤វីដេអូ

- វេទិកាស្វែងយល់ពីកសិកម្មផលិតចំនួន ២ប្រធានបទ និងចាក់ផ្សាយចំនួន ១២លើក

- នាទីចុះស្រែជាមួយកសិករផលិតចំនួន ២វីដេអូ និងចាក់ផ្សាយចំនួន ១២លើក

- នាទីកសិករជួបជាមួយកសិករផលិតបានចំនួន ១ឯកសារ និងចាក់ផ្សាយចំនួន ៦លើក

- ផលិតឯកសារបច្ចេកទេសចំនួន ២មុខ គឺកូនសៀវភៅណែនាំស្តីពីបច្ចេកទេសចិញ្ចឹមពពែចំនួន ៤ ០០០ច្បាប់ និងកូនសៀវភៅណែនាំស្តីពីបច្ចេកទេសចិញ្ចឹមក្រួចចំនួន ៤ ០០០ច្បាប់

- ចងក្រង និងបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានកសិកម្ម គឺបទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹម និងភ្ញាស់កូនបង្កងលក់ចំនួន ១ ០០០ច្បាប់ និងបទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹម និងភ្ញាស់ពងទាកូនលក់ចំនួន ១ ០០០ច្បាប់

- ផ្សព្វផ្សាយវីដេអូ និងឯកសារបច្ចេកទេសកសិកម្មចំនួន ១ ០៥១ឯកសារ

- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មនានាដល់កសិករ និងអតិថិជនចំនួន ១៤៦សំណួរចម្លើយមកពី២៥រាជធានី-ខេត្ត

- ចុះប្រមូល ចងក្រង និងថតវីដេអូ ដើម្បីផលិតឯកសារការអនុវត្តល្អរបស់កសិករក្នុងសហគមន៍គោលដៅរបស់គម្រោងលើមុខទំនិញ៣ប្រភេទ គឺ ស្វាយកែវរមៀត ការកែច្នៃមៀនប៉ៃលិន និងអាជីវកម្មស្វាយចន្ទី

- ផ្តល់វគ្គបណ្តុះបណ្តាលអំពីផលិតកម្មសត្វមាន់លើរបៀបការប្រើប្រាស់វ៉ាក់សាំង និងរបៀបធ្វើទូរភ្ញាស់ស៊ុតចំនួន ១វគ្គ មានអ្នកចូលរួមចំនួន ៤៧នាក់

- ផ្តល់វគ្គបណ្តុះបណ្តាលអំពីផលិតកម្មដំណាំបន្លែ និងដំណាំស្រូវចំនួន ១វគ្គ មានអ្នកចូលរួមចំនួន ៤៧នាក់។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- ចូលរួមកិច្ចប្រជុំសរុបចំនួន ១៣៥លើក សិក្ខាសាលាសរុបចំនួន ១៩លើក និងចូលរួមវគ្គបណ្តុះបណ្តាលសរុបចំនួន ៧លើក

- ចុះផ្សព្វផ្សាយ សិក្សា និងប្រមូលផលទិន្នន័យបឋមអំពីការយល់ដឹង និងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តមណ្ឌលគិរី និងខេត្តរតនគិរី

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅទីផ្សារតាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តព្រៃវែង និងខេត្តរតនគិរី

- ចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតកម្មកសិកម្មនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់

- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តកំពង់ធំ និងខេត្តព្រះសីហនុ

- ចុះបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបុគ្គលិកសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ អំពីប្រព័ន្ធគុណភាព និងសុវត្ថិភាពចំណីអាហារ (HACCP) ប្រព័ន្ធគ្រប់គ្រងសរីរាង្គ និងត្រួតពិនិត្យលើផលិតកម្មសម្រាប់ការនាំចេញទៅកាន់ទីផ្សារប្រទេសជប៉ុន

- ចុះសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មរវាងកសិករ និងសហគមន៍អភិវឌ្ឍន៍កសិកម្មកម្ពុជាលើកិច្ចសន្យាដាំដុះចំបក់បារាំង (Macadamia) និងស្លឹកគ្រៃក្រអូប

- បាននិងកំពុងធ្វើកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីធ្វើពិសោធន៍ និងតាមដានការថយចុះនូវកំហាប់ថ្នាំពុលកសិកម្ម (pesticide decline) ដែលនឹងអនុវត្តទៅលើដំណាំស្រូវ និងដំណាំជីក្រហម (Sweet Basil)

- ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៩-២០៣០ ជូនដល់អង្គភាពពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍន៍នានា

- បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់នេះចំនួន ១៨លើក ក្នុងនោះប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃនាយកដ្ឋានកសិ-ឧស្សាហកម្មចំនួន ៨លើក ប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ៧លើក ប្រជុំគណៈកម្មការបច្ចេកទេសរៀបចំតាក់តែងច្បាប់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ២លើក និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ចំនួន ១លើក

- ប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីវិធានអនុវត្តអនាម័យល្អ (GHP) និងស្លាកសញ្ញាសម្គាល់សម្រាប់ផលិតផលកសិកម្ម និងចំណីអាហារនៃផលិតផលកសិកម្ម

- ជួយរៀបចំ និងផ្តល់យោបល់សម្រាប់ការិយាល័យកសិ-ឧស្សាហកម្មរាជធានី-ខេត្ត ស្តីពីការរៀបចំសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មជូនភាគីអ្នកទិញ និងភាគីអ្នកផលិត

- វឌ្ឍនភាពការងារកិច្ចសន្យាផលិតកម្មកសិកម្មបណ្តារាជធានី-ខេត្តដែលបានអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មក្នុងឆ្នាំ២០២១នេះ រួមមាន៖ ខេត្តបន្ទាយមានជ័យចំនួន ៤កិច្ចសន្យា កំពង់ឆ្នាំងចំនួន ២៦កិច្ចសន្យា កំពង់ស្ពឺចំនួន ៤៨៤កិច្ចសន្យា កំពង់ធំចំនួន ៣៦កិច្ចសន្យា ក្រចេះចំនួន ១១កិច្ចសន្យា មណ្ឌលគិរី ១៤កិច្ចសន្យា ព្រះវិហារ ៤៣កិច្ចសន្យា ព្រៃវែងចំនួន ១កិច្ចសន្យា សៀមរាបចំនួន ៥កិច្ចសន្យា ព្រះសីហនុចំនួន ១៩កិច្ចសន្យា ស្ទឹងត្រែងចំនួន ៩៥កិច្ចសន្យា ស្វាយរៀងចំនួន ១កិច្ចសន្យា ប៉ៃលិនចំនួន ១៦កិច្ចសន្យា ឧត្តរមានជ័យ ៤កិច្ចសន្យា ត្បូងឃ្មុំចំនួន ៤០កិច្ចសន្យា ពោធិ៍សាត់ចំនួន ៦៦កិច្ចសន្យា បាត់ដំបងចំនួន ១៤កិច្ចសន្យា និងខេត្តកែបចំនួន ២១កិច្ចសន្យា សរុបចំនួន ៩០០កិច្ចសន្យា

- ធ្វើការវិភាគនូវសមាសធាតុគីមី កំហាប់អំបិល pH និងបាក់តេរីបង្កគ្រោះថ្នាក់ (អ៊ីកូលី, Total Plate count) នៅក្នុងទឹកចំនួន ៤ប្រភេទផ្សេងៗគ្នាដែលទទួលបានពីអតិថិជន

- ធ្វើការវិភាគនូវសមាសធាតុលោហៈធ្ងន់ រួមមាន៖ អាសេនិច បារត និងសំណនៅក្នុងសំណាកត្រីទឹកសាបចំនួន ១៤ប្រភេទផ្សេងៗគ្នា ព្រមទាំងបាក់តេរីបង្កគ្រោះថ្នាក់ រួមមាន៖ វត្តមានអ៊ីកូលី សាល់ម៉ូណេឡា និង *Enterobacteriaceae* ទៅលើផលិតផលនីមួយៗ

- ធ្វើការវិភាគនូវសមាសធាតុគីមី រួមមាន៖ ថាមពល ប្រូតេអ៊ីន ជាតិសរសៃ ស្ករ ខ្លាញ់ អាស៊ីត pH កាល់ស្យូម សូដ្យូម ប៉ូតាស្យូម កាបូនអ៊ីដ្រាតនៅក្នុងហ្វីស៊ីបគោ

- ធ្វើការវិភាគនូវលោហៈធ្ងន់ កំហាប់អាសេនិចនៅលើបន្លែស្រស់ដែលត្រូវបានប្រមូលមកពីផ្សារចំនួន ៣នៅរាជធានីភ្នំពេញ ដោយក្នុងមួយផ្សារយកបន្លែចំនួន ១០ប្រភេទខុសៗគ្នា។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ប្រមូលប្រភេទពូជដំណាំថ្មីៗបានចំនួន ១៥ប្រភេទ សរុបមានចំនួន ១០៦សំណាក (ត្រសក់២៨សំណាក ល្ពៅ ៣៤សំណាក ឪឡឹក២សំណាក ត្រប់៤សំណាក ម្ទេស២សំណាក ចេក៩សំណាក អំពៅ៦សំណាក ដំឡូងផ្វា៩សំណាក ដំឡូងឈាមមាន់២សំណាក ដំឡូងដៃខ្លា១សំណាក ត្រាវ១សំណាក សណ្តែក១សំណាក ពោត១សំណាក ស្វាយ ៥សំណាក និងស្វាយចន្ទី៥សំណាក) មករក្សាទុកក្នុងធនាគារពន្ធុរបស់វិទ្យាស្ថាន និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានបានចំនួន ៣៩ប្រភេទដែលរួមមានស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៨ប្រភេទសរុបចំនួន ២ ៥១៧បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៩ ២៩៣បញ្ជីក/សំណាក។ ដាំវាយតម្លៃ និងកំណត់លក្ខណៈលើ

ដំណាំ៥មុខ គឺ មេឡុងចំនួន ៥០សំណាក ម្ទេសចំនួន ៥០សំណាក ល្ពៅចំនួន ៣០សំណាក ត្រប់ចំនួន ៤០សំណាក និង ជំឡូងផ្វាចំនួន ៣៦សំណាកសរុបមានចំនួន ២០៦សំណាក

- ធ្វើពិសោធន៍ចំនួន ៩៧ប្រភេទនៅ៥៣៥កន្លែង ក្នុងនោះ មានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញ ចំនួន ២៥៩កន្លែង

- ផ្តល់បទសម្ភាសន៍តាមទូរស័ព្ទដល់កាសែត កោះសន្តិភាព កម្ពុជាថ្មី ភ្នំពេញប៉ុស្តិ៍ ខ្មែរថែម Business Cambodia និងទាក់ទងនឹងឯកសារផ្សព្វផ្សាយលើប្រធានបទ៖ ១.គម្រោងស្រាវជ្រាវស្តីពីពិពិធកម្មប្រជាករស្រូវសែនក្រអូប ២. គម្រោងស្រាវជ្រាវស្តីពីបសិដ្ឋកម្មពូជស្រូវក្រអូបមិនប្រកាន់រដូវ ៣.គម្រោងស្រាវជ្រាវស្តីពីការពង្រីកវិសាលភាពដាំដុះពូជស្រូវផ្កាមាលតី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

- រៀបចំបើកវគ្គបណ្តុះបណ្តាលកសិករចំនួន ២៦លើក មានកសិករចូលរួមចំនួន ១ ១៤៦នាក់ (ស្រី៧០៤នាក់ ស្មើនឹង៦១%) ជួបប្រជុំ និងធ្វើទិវាស្រែបង្ហាញចំនួន ១៨លើកមានកសិករចូលរួម ៧០៧នាក់ (ស្រី៣៥៦នាក់ ស្មើនឹង៥០%) ចែកពូជស្រូវក្នុងចំណាត់ថ្នាក់ពូជស្រូវសុទ្ធល្អសរុបចំនួន ៨០០គ.ក្រដល់កសិករនៅខេត្តសៀមរាប និងខេត្តព្រៃវែងសម្រាប់ការងារបង្កបង្កើនផលស្រូវឆ្នាំ២០២១ជាពូជស្រូវធានាបាននូវភាពសុទ្ធ និងទិន្នផលខ្ពស់

- ក្នុងរយៈពេលមួយឆ្នាំ២០២១នេះ មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ១ ០២៩ ៩២៣នាក់ ហើយគិតជាមធ្យមមានប្រមាណ២ ៨២២នាក់/ថ្ងៃ

- បើកវគ្គបណ្តុះបណ្តាលជំនាញនៅវិទ្យាស្ថាន CARDI ចំនួន៨វគ្គ/លើក មានសិក្ខាកាមចូលរួមចំនួន ១៣២នាក់ (ស្រី៣៧នាក់ ស្មើនឹង២៨%)

- ចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំនៅក្នុងប្រទេស៦៤លើក ដែលមានអ្នកចូលរួមសរុបចំនួន ១៨៦នាក់ (ស្រី៥១នាក់ ស្មើនឹង២៧%) និងមានមន្ត្រីសរុបចំនួន៤រូបទៀតបាននិងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន២រូប និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន២រូបនៅប្រទេសកូរ៉េ ជប៉ុន និងប្រទេសចិន។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- រៀបចំប្រជុំពិភាក្សាស្តីពីការធ្វើសេចក្តីព្រាងគោលការណ៍ណែនាំសម្រាប់ការស្នើសុំរៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- ចុះកិច្ចព្រមព្រៀងអនុស្សរណៈជាមួយក្រុមហ៊ុន Smart Axiata ក្រុមហ៊ុន IHPP (Cambodia) Impact Hub (Cambodia) លើកម្មវិធីសិក្សា SmartStart Unipreneur Learning Platform (ULP)

- ចូលរួមប្រជុំជាមួយ CGCC ស្តីពីការសហការសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការប្រព័ន្ធជីវឧស្ម័ន និងជួបប្រជុំជាមួយនឹងក្រុមហ៊ុនអាល្លឺម៉ង់ BINDER GROUP ជដៃគពិភាក្សាលើផលិតផល និងសេវាកម្មលើវិស័យបច្ចេកវិទ្យាជីវឧស្ម័ន

- រៀបចំសិក្ខាសាលាស្តីពី Identifying the Institutional Outcomes and Educational Philosophy of Graduate Programs ជាមួយសាកលវិទ្យាល័យហ្វីលីពីន ដើម្បីពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលនៅថ្នាក់ក្រោយបរិញ្ញាបត្រ

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំប្លង់មេរៀនលំអិតលើមុខវិជ្ជាផលិតកម្មបក្សី ភាពស៊ាំវិទ្យា និង រោគសាស្ត្រសត្វ សុខភាពសាធារណៈ បសុរោគវិនិច្ឆ័យគ្លីនិច វេជ្ជអេពីដេមីសាស្ត្រនិងអនាម័យសាច់ និងសុវត្ថិភាពចំណីអាហារ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៥៥២នាក់ (ស្រី២២៨នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយ និងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធចិញ្ចឹមគោទឹកដោះ ការពិសោធចិញ្ចឹមបង្គា ការពិសោធបង្កាត់ពូជមាន់ ការសិក្សាពិសោធថ្នាំបណ្តេញសត្វល្អិត ការពិសោធចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់កេសរកូល

ការពិសោធដំណាំព្រីង ការសិក្សាពិសោធផលិតម្សៅឬស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវាក់តម្លៃស្វាយចន្ទី

- រៀបចំពិធីប្រឡងបញ្ចប់ការសិក្សានិស្សិតថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រគ្រប់ជំនាញប្រកបដោយជោគជ័យ
- រៀបចំកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់៥ជំនាញចប់ជាស្ថាពរ និងបានការគាំទ្រពីក្រសួងអាណាព្យាបាល និងបានស្នើសុំការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រើប្រាស់ជាផ្លូវការ
- ចូលរួមជាវាគ្មិនថ្លែងសុន្ទរកថាបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពីរបាយការណ៍សិក្សាស្រាវជ្រាវអំពីការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- ចុះសិក្សាអំពីវត្ថុធាតុដើមសម្រាប់ធ្វើថ្នាំពុលកសិកម្មធម្មជាតិចំនួន ១០លើកមានមន្ត្រីចំនួន ៤៩នាក់ ក្នុងនោះមានជនជាតិអាមេរិកកាំងចំនួន ១នាក់
- សាងសង់ SMART FARM នៅក្នុងវិទ្យាស្ថានជាតិ និងកំពុងដំណើរការដាំបន្លែ និងចិញ្ចឹមត្រី។

## ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៦១០នាក់ (ស្រី២៧៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- ត្រៀមការពារសារណាបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មផ្នែកអាហារូបករណ៍ជំនាន់ទី១៥ និងផ្នែកបណ្តុះបណ្តាលបន្តជំនាន់ទី១៨
- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- ធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- ធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប
- ចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

## ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានអនុវត្ត បន្តការងារស្រាវជ្រាវ និងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសរុបមាន៦២ពិសោធន៍។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្សដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ បណ្តុះបណ្តាលនូវធនធានមនុស្សតាមរយៈការបង្ហាត់បង្រៀននិស្សិតនៅតាមគ្រឹះស្ថានសិក្សា និងការសម្របសម្រួលឱ្យនិស្សិតចុះធ្វើទស្សនកិច្ចសិក្សាចម្ការពិសោធន៍ និងការដឹកនាំធ្វើសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត
- រៀបចំចម្ការពិសោធន៍ក្នុងផ្នែកដាំដុះ និងការពារគីដើម្បីធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រដាំដុះ ការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងជីជាតិដី បង្កើនប្រសិទ្ធភាពនៃចម្ការ ការប្រើប្រាស់ដី បង្កើតនូវចំណូលបន្ថែមតាមរយៈការធ្វើពិពិធកម្មកៅស៊ូជាមួយប្រភេទដំណាំ និងរុក្ខជាតិផ្សេងទៀតដោយមានការសិក្សាអំពីទំនាក់ទំនងរវាងការលូតលាស់ និងទិន្នផលរួមជាមួយនិងកត្តាអាកាសធាតុ។ អនុវត្តការងារបំប៉ៅកូនកៅស៊ូសម្រាប់ដាំដុះឆ្នាំ២០២១ និងដាំជួសកៅស៊ូដាំឆ្នាំ២០១៩-២០២០ រៀបចំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០២១ លើផ្ទៃដី០,៣៥ហ.ត អនុវត្តការថែទាំដំណាំគ្របដីចំនួន៣ប្រភេទ(*Stylosanthes guianesis, Mucuna aterrinum, Puraria phaseoloides*) ដាក់ជីបំប៉នលើកូនកៅស៊ូមិនទាន់ផ្តល់ផលចំនួន២លើកលើផ្ទៃដី៣៧,៧៥ហ.ត និងចម្ការពិសោធន៍ដីលើកៅស៊ូផ្តល់ផលចំនួន ៤ចម្ការលើផ្ទៃដី១៥,២០ហ.ត បាញ់ថ្នាំការពារនិងព្យាបាលជំងឺផ្សិតនៅតាមប្រគៀបមែកលើកៅស៊ូដែលមានអាយុពី៤-១០ឆ្នាំលើផ្ទៃដី១៦១.៦៦ហ.ត និងដាំដុះកូនកៅស៊ូក្នុងឆ្នាំ២០២១លើផ្ទៃដីចំនួន៩.៥ហ.ត
- តាមដានស្រង់និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ចំនួន ២៣ចម្ការពិសោធន៍។ ការស្រាវជ្រាវការអភិវឌ្ឍធនធានក្លូនកៅស៊ូកម្ពុជាធនធានសេនេទិច (genotype) កៅស៊ូលេចធ្លោចំនួន២០ត្រូវបានជ្រើសរើសសម្រាប់ការបង្កើតចម្ការពិសោធន៍ទ្រង់ទ្រាយតូច និងដាំនៅចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយតូច ដោយធ្វើការប្រៀបជាមួយបណ្តាក្លូនកសិណរួមមាន GT1, PB 260, RRIM 600 និង PB 217។ បន្ទាប់ពីការចៀរជ័រសាកល្បងរយៈពេល១០ខែ សំណួទីបចំនួន១២

បានបង្ហាញអំពីការលូតលាស់ ទិន្នផល និងលក្ខណៈសរីរទឹកជ័រ (Suc, R-SH, Thiol) ល្អជាងបណ្តាក្លូនកសិណ ហើយក្នុងនោះមានសេណូទីបចំនួន២បានបង្ហាញពីភាពល្អដាច់គេក្នុងចំណោមសេណូទីបទាំង១២ នេះបញ្ជាក់ថាសេណូទីបទាំងនោះជាក្តីរំពឹងក្នុងការបង្កើត និងទទួលបានក្លូនកៅស៊ូកម្ពុជាដ៏ល្អនាពេលអនាគត។ ការអនុវត្តថែទាំច្បារពូជកៅស៊ូទំហំ៨,៦០ហ.តសម្រាប់បម្រើដល់ការពិសោធស្រាវជ្រាវ និងដាំពង្រីកកូនកៅស៊ូនៅក្នុងច្បារពូជសរុបចំនួន៧៧៩កូន។

- តាមដានស្រង់បញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន១៣ និងក្រៅស្ថានីយចំនួន១(ទំហំដើម ទិន្នផល និងជំងឺស្ងួតមុខចៀរ TPD)។ ការវិភាគសរីរទឹកជ័រ (Latex Diagnosis) ក្នុងមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យាកៅស៊ូគឺបានយកសំណាក និងវិភាគសរីរទឹកជ័រពីចម្ការពិសោធន៍នានាក្នុងនិងក្រៅស្ថានីយបានចំនួន ២៩ចម្ការពិសោធន៍ស្មើនឹង ១ ២៨០សំណាក

- រៀបចំឯកសារស្តង់ដារ ISO/IEC 17025: 2017 អនុវត្តការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017 ធ្វើតេស្តកៅស៊ូសន្លឹក (RSS) សរុបចំនួន ៧២សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CSR ចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍អន្តរជាតិក្នុងក្របខ័ណ្ឌសមាគមន៍កៅស៊ូអន្តរជាតិ (IRA) ចំនួន២លើក ធ្វើតេស្តប្រៀបធៀបក្នុងស្រុកជាមួយមន្ទីរសោធន៍មូលដ្ឋានលើកទី៦២ចំនួន ៤២សំណាក និងចុះបញ្ជិកាទទួលស្គាល់ និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាចំនួន៤ រោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ចំនួន៣។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៩០១ ៦០៥ហ.ត ស្មើនឹង១១១,២១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត និងការប្រមូលផលស្រូវវស្សាសម្រេចចំនួន ២ ៧៨២ ៩៤៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៩ ០៦០ ៤៩៥តោន លើសឆ្នាំមុនចំនួន ៨៤០ ៨១៨តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,២៥៦តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវប្រាំង
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំលោភយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**